ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រម**

លេខ ២៣២ "ច" ក្រ២

ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០២៣

សំណុំរឿងព្រហ្មទណ្ឌលេខ ៣៧៦៧

ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០២២

ស៊ើបសួរលេខ ២៨៧៦

ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០២២

ជំនុំជម្រះលេខ ៤៧

ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០២៣

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០២៣

វេលាម៉ោង ៨ និង ០០ នាទីព្រឹក ដោយមានសមាសភាព:

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ចៅក្រមក្រុមប្រឹក្សា

លោកស្រី [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ចៅក្រមក្រុមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៧៦៧ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០២២ ដែលមានជនជាប់ចោទឈ្មោះ [redacted] **ឥស្សរា** ភេទប្រុស អាយុ ១៩ ឆ្នាំ (១៣.០៤.២០០៣) សញ្ជាតិខ្មែរ មុខរបរៈ សិស្ស ទីកន្លែងកំណើតនៅសង្កាត់ [redacted] រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះលេខ១៩០ ផ្លូវបេតុង សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] ពៅធារិទ្ធ "រ" ម្តាយឈ្មោះ [redacted] ចិន្តា "រ" ជានីតិជន ទោសពីមុនគ្មាន ។

ឃាត់ខ្លួនថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០២២ , ឃុំខ្លួនថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០២២ (ម១)

ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្លូវលេខ៣១៥ កែងផ្លូវលេខ៥៦៦ ក្រុម៣៨ ភូមិ៩ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០២២ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] JIYOUNG ភេទស្រី ឆ្នាំ ១៩៩៥ ជនជាតិកូរ៉េ មានទីលំនៅបច្ចុប្បន្ន ស្នាក់នៅខុនដូរ JCITY លេខ៣៥ ផ្លូវលេខ៣២២ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

### អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០២២ វេលាម៉ោងប្រហែល ១៧ និង ៣០ នាទី នៅចំណុចផ្លូវលេខ៣១៥ កែងផ្លូវលេខ៥៦៦ ក្រុម៣៨ ភូមិ៩ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ពិតជាមានករណីលួចមានស្ថានទម្ងន់ទោស



Scanned with CamScanner

ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ឥស្សរា ភេទប្រុស អាយុ ១៩ ឆ្នាំ ខណៈពេលជនរងគ្រោះឈ្មោះ [redacted] JIYOUNG ភេទស្រី អាយុ ២៧ ឆ្នាំ កាន់កាបូបស្ពាយចំហៀងចេញពីហាងកាហ្វេ BROWN ជាមួយមិត្តប្រុសបម្រុងឆ្លងផ្លូវលេខ៣១៥ កែងផ្លូវលេខ៥៦៦ ក្រុម៣៨ ភូមិ៩ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីថតរូបលេង ស្រាប់តែជនជាប់ចោទឈ្មោះ [redacted] ឥស្សរា បានជិះម៉ូតូមួយគ្រឿងមកក្បែរជនរងគ្រោះ រួចធ្វើសកម្មភាពឆក់កាបូបខាងលើបានសម្រេច ហើយក៏ជិះគេចខ្លួនជ្រុលទៅបុកជាមួយ ផាស់អាប់ បណ្ដាលឱ្យដួលម៉ូតូ ទើបជនរងគ្រោះ និងមិត្តប្រុសចាប់ឃាត់ខ្លួនជនជាប់ចោទបាន យកទៅប្រគល់ឱ្យសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលបឹងកក់ទី១ ដើម្បីចាត់ការតាមច្បាប់ ។

បានឃើញរបាយការណ៍សំយោគលេខ ០៩៣/២២ រ.ប.ក ចុះថ្ងៃទី០២ ខែ សីហា ឆ្នាំ ២០២២ របស់អធិការដ្ឋាននគរបាលខណ្ឌទួលគោក ។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរលេខ ២៨៧៣ អ.យ.ន ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៤៦៦៧ អ.យ.ន ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៦២៤៦ "ន" ស.ង ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## នាពេលសវនាការ

ជនជាប់ចោទឈ្មោះ [redacted] **ឥស្សរា** បានឆ្លើយថា៖ កាលពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០២២ វេលាម៉ោង ០៣ និង ៣០ នាទី ខ្លួនបានចេញពីញ៉ាំអីជាមួយមិត្តភក្តិនៅម្តុំផ្សារឈូកមាស រួចក៏ជិះម៉ូតូត្រឡប់ទៅផ្ទះវិញ ពេលជិះដល់ផ្លូវលេខ ៣១៥ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឃើញជនបរទេសស្រីម្នាក់ និងប្រុសម្នាក់នៅចិញ្ចើមផ្លូវ ដោយស្ត្រីជនរងគ្រោះ មានស្ពាយកាបូបពណ៌ខ្មៅ កៀបនៅក្លៀកផ្នែកខាងស្តាំ ដោយឃើញសភាពស្ងាត់ ខ្លួនជិះម៉ូតូទៅអែបខាងឆ្វេងដៃ រួចខ្លួនបានឆក់កាបូបស្ពាយជនរងគ្រោះនោះបានសម្រេច រួចជិះម៉ូតូគេចខ្លួនបាន ១០០ម៉ែត្រ ដល់ចំណុចផ្លូវលេខ ៣១៥ កែងផ្លូវ ៥៦៦ ក៏មាន PASS APP បុករួចជ្រុលទៅបុកជាមួយនឹងរថយន្តដែលចតចោលបណ្ដាលឲ្យដួល ភ្លាមនោះ ស្រាប់តែជនបរទេសជាមនុស្សប្រុសដែលនៅជាមួយជនរងគ្រោះរត់មកយកកាបូបពីដៃខ្លួនទៅវិញ ហើយក៏មានប្រជាពលរដ្ឋក្បែរនោះ បានមកឃាត់រូបខ្លួនព្រមទាំងវាយម្នាក់មួយដៃមួយជើង រួចសមត្ថកិច្ចប៉ុស្តិ៍នគរបាលបឹងកក់ទី១បានចុះមកដល់ហើយធ្វើការឃាត់រូបខ្លួន និងធ្វើការដកហូត ទូរស័ព្ទមួយគ្រឿងម៉ាក IPHONE X និងម៉ូតូមួយគ្រឿង ម៉ាក HONDA CUB ។

ក្រឡាបញ្ជីអានចម្លើយជនរងគ្រោះឈ្មោះ [redacted] JIYOUNG បានឆ្លើយនៅសមត្ថកិច្ចថា៖ កាលពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០២២ វេលាម៉ោងប្រហែល ១៦ និង ៤៥ នាទី ខ្លួនបានដើរចេញពីហាងកាហ្វេ BROWN ស្ថិតនៅផ្លូវលេខ ៣១៥ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ជាមួយមិត្តប្រុសរបស់ខ្លួនឈ្មោះ [redacted] JAE WOO ភេទប្រុស អាយុ ៣៣ ឆ្នាំ ជនជាតិកូរ៉េ ក្នុងគោលបំណងដើរថតរូបតាមដងផ្លូវ ។ លុះដល់វេលាម៉ោង ១៧ និង ០០ នាទី ពួកខ្លួនដើរមកដល់ចំណុចផ្លូវលេខ ៣១៥ កែងផ្លូវ ៥៦៦ ដើម្បីឈរចាំរឺម៉កម៉ូតូ ខ្លួនបានយកកាបូបស្ពាយចំហៀងពណ៌ខ្មៅមកគៀបជាប់ក្លៀកខាងស្តាំឈរបំរុងនឹងឆ្លងផ្លូវ ។ ស្រាប់តែមានជនជាប់ចោទម្នាក់ភេទប្រុស ជិះម៉ូតូមួយគ្រឿង ម៉ាក HONDA គុបជ្រុង ពណ៌ខៀវ មកអែបខាងឆ្វេងដៃរបស់ខ្លួន



Scanned with CamScanner

ហើយឆក់កាបូបរបស់ខ្លួនបានសម្រេច រួចជិះគេចខ្លួន ពេលដែលជនសង្ស័យជិះគេចខ្លួនក៏ជ្រុលទៅបុក PASS APP បណ្តាលឱ្យជនសង្ស័យដួលភ្លាមនោះ ខ្លួន និងមិត្តប្រុសខ្លួនធ្វើការឃាត់ខ្លួនជនសង្ស័យបាន រួចប្រគល់ឱ្យសមត្ថកិច្ចតែម្តង ។

ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ [redacted] JAE WOO បានឆ្លើយថា៖ កាលពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០២២ វេលាម៉ោងប្រហែល ១៦ និង ៤៥ នាទី ខ្លួនបានដើរចេញពីហាងកាហ្វេ BROWN ស្ថិតនៅផ្លូវលេខ ៣១៥ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ជាមួយមិត្តស្រីរបស់ខ្លួនឈ្មោះ [redacted] JIYOUNG ក្នុងគោលបំណងចាំ PASS APP ដោយមិត្តស្រីរបស់ខ្លួនស្ពាយកាបូបចំហៀងពណ៌ខ្មៅមកគៀបជាប់ក្លៀកខាងស្តាំ ស្រាប់តែមានជនសង្ស័យម្នាក់ភេទប្រុស ជិះម៉ូតូមួយគ្រឿង ម៉ាក HONDA គុបជ្រុង ពណ៌ខៀវ មកអែបខាងឆ្វេងដៃមិត្តស្រីរបស់ខ្លួន ហើយឆក់កាបូបបានសម្រេច រួចជិះគេចខ្លួន ពេលដែលជនសង្ស័យជិះគេចខ្លួនក៏ជ្រុលទៅបុក PASS APP បណ្តាលឱ្យជនសង្ស័យដួលភ្លាមនោះ ខ្លួន និងមិត្តស្រីខ្លួនធ្វើការឃាត់ខ្លួនជនសង្ស័យបាន រួចប្រគល់ឱ្យសមត្ថកិច្ចតែម្តង ។

**តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ**

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ និងអំណានចម្លើយជនរងគ្រោះ ឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] ឥស្សរា ភេទប្រុស អាយុ ១៩ឆ្នាំ (១៣.០៤.២០០៣) ពិតជាបានប្រព្រឹត្តអំពើលួចមានស្ថានទម្ងន់ទោស កាលពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០២២ ពិតប្រាកដមែន ។ ដូច្នេះតំណាងអយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៤៦៦៧ អ.យ.ន ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០២២ ដដែល សូមតុលាការពិនិត្យពិចារណា និងសម្រេចតាមច្បាប់ ។

**មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋាន**

នៅក្នុងរឿងនេះ កូនក្តីខ្លួនបានឆ្លើយនៅចំពោះមុខអង្គសវនាការថា ខ្លួនពិតជាបានប្រព្រឹត្តអំពើលួចមានស្ថានទម្ងន់ទោស (ឆក់យកកាបូកស្ពាយចំហៀងរបស់ជនរងគ្រោះមែន) ដោយសារតែកត្តាជីវភាព និងការយល់ដឹងរបស់ជនជាប់ចោទមានកំរិតទាប ទើបបណ្តាលឱ្យកូនក្តីខ្លួនគិតខ្លីមួយរយៈពេល ។ ហេតុនេះ សុំឱ្យតុលាការគិតពីស្ថានសម្រាលទោសដល់កូនក្តីខ្លួនផង ។

**ជនជាប់ចោទបាននិយាយសំដីចុងក្រោយ**

សុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

ក្រោយពីបានស្តាប់អំណានចម្លើយជនរងគ្រោះ

ក្រោមពីបានស្តាប់អំណានចម្លើយសាក្សី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាង

ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**<u>សំអាងហេតុ</u>**

១. តាមរបាយការណ៍របស់អធិការដ្ឋាននគរបាលខណ្ឌទួលគោក និងភស្តុតាងទាំងអស់ដែលស្វែងរកដោយចៅក្រមស៊ើបសួរ ពុំមានភាពផ្ទុយគ្នាទេ ។ យោងតាមមាត្រា ១១០ និងមាត្រា ១១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ អាចឱ្យតុលាការជឿបានថា កាលពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០២២ វេលាម៉ោងប្រហែល ១៧ និង ៣០ នាទី នៅចំណុចផ្លូវលេខ៣១៥ កែងផ្លូវលេខ៥៦៦ ក្រុម៣៨ ភូមិ៩ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ពិតជាមានករណីលួចមានស្ថានទម្ងន់ទោស ដែលបង្ក



Scanned with CamScanner

ឡើងដោយជនជាប់ចោទឈ្មោះ [redacted] ឥស្សរា ភេទប្រុស អាយុ ១៩ ឆ្នាំ ខណៈពេលជនរងគ្រោះឈ្មោះ [redacted] JIYOUNG ភេទស្រី អាយុ ២៧ ឆ្នាំ កាន់កាបូបស្ពាយចំហៀងចេញពីហាងកាហ្វេ BROWN ជាមួយមិត្តប្រុសបម្រុងឆ្លងផ្លូវលេខ៣១៥ កែងផ្លូវលេខ៥៦៦ ក្រុម៣៨ ភូមិ៩ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីថតរូបលេង ស្រាប់តែជនជាប់ចោទឈ្មោះ [redacted] ឥស្សរា បានជិះម៉ូតូមួយគ្រឿងមកក្បែរជនរងគ្រោះ រួចធ្វើសកម្មភាពឆក់កាបូបខាងលើបានសម្រេច ហើយក៏ជិះគេចខ្លួនជ្រុលទៅបុកជាមួយ ផាស់អាប់ បណ្ដាលឱ្យដួលម៉ូតូ ទើបជនរងគ្រោះ និងមិត្តប្រុសចាប់ឃាត់ខ្លួនជនជាប់ចោទបាន យកទៅប្រគល់ឱ្យសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលបឹងកក់ទី១ ដើម្បីចាត់ការតាមច្បាប់ ។

២. តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ឥស្សរា បានឆ្លើយសារភាពនាពេលសវនាការថា៖ កាលពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០២២ ខ្លួនពិតជាបានធ្វើសកម្មភាពប្រព្រឹត្តអំពើលួចមានស្ថានទម្ងន់ទោស (ឆក់យកកាបូបស្ពាយ) ដូចការចោទប្រកាន់របស់តំណាងអយ្យការមែន ដែលចម្លើយសារភាពរបស់ជនជាប់ចោទ ស្របនឹងចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] JIYOUNG និងសាក្សីឈ្មោះ [redacted] JAE WOO និងរបាយការណ៍របស់សមត្ថកិច្ចមន្ត្រីនគរបាលយុត្តិធម៌ខណ្ឌទួលគោក ដែរ ។

ភស្តុតាងទាំងអស់នេះតុលាការអាចលើកយកមកពិចារណាបានតាមមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣. ជនជាប់ចោទឈ្មោះ [redacted] ឥស្សរា ជានីតិជនមានស្មារតីគ្រប់គ្រាន់ នៅពេលប្រព្រឹត្តបទល្មើសពុំមានជំងឺវិបល្លាសស្មារតីទេ ។ ជាសមត្ថជនមានសមត្ថភាពពេញលេញក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួនតាមផ្លូវច្បាប់ ។ ស្របតាមមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ ។

៤. អំពើប្រព្រឹត្តរបស់ជនជាប់ចោទ បានធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយ សណ្ដាប់ធ្នាប់សាធារណៈសន្តិសុខសង្គម ដែលក្រមព្រហ្មទណ្ឌត្រង់មាត្រា ២ និង ៣ បានហាមឃាត់ដាច់ខាត និងត្រូវតែផ្ដន្ទាទោស ។ ម្យ៉ាងទៀត អំពើនេះមានធាតុផ្សំគ្រប់គ្រាន់ពីបទៈ លួចមានស្ថានទម្ងន់ទោស ។

៥. ជនរងគ្រោះឈ្មោះ [redacted] JIYOUNG មិនបានតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីប្ដឹងទាមទារសំណងការខូចខាតអ្វីទេ ។ ពុំគប្បីតុលាការពិចារណាសម្រេចអំពីសំណងទេ ។

៦. វត្ថុចាប់យកមាន៖ ម៉ូតូម៉ាកគុបជ្រុង ពណ៌ខៀវ ផ្លាកលេខ ភ្នំពេញ 1ID-9268 ចំនួន ០១គ្រឿង (មិនប្រក្រតី) ។

គប្បីតុលាការពិនិត្យ និងសម្រេច ។

៧. មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ឥស្សរា ភេទប្រុស អាយុ ១៩ ឆ្នាំ (១៣.០៤.២០០៣) ពីបទលួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្លូវលេខ៣១៥ កែងផ្លូវលេខ៥៦៦ ក្រុម៣៨ ភូមិ៩ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

**ហេតុដូច្នេះសម្រេច**

១. ផ្ដន្ទាទោសលើឈ្មោះ [redacted] **ឥស្សរា** ភេទប្រុស អាយុ ១៩ ឆ្នាំ (១៣.០៤.២០០៣) សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣(បីឆ្នាំ) ។

ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្លូវលេខ៣១៥ កែងផ្លូវលេខ៥៦៦ ក្រុម៣៨ ភូមិ៩ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

២. វត្ថុចាប់យកមាន៖ ម៉ូតូម៉ាកគុបជ្រុង ពណ៌ខៀវ ផ្លាកលេខ ភ្នំពេញ 1ID-9268 ចំនួន ០១គ្រឿង (មិនប្រក្រតី) ។



Scanned with CamScanner

សម្រេចប្រគល់ឲ្យម្ចាស់ដើមវិញ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០២៣ ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០២៣ ។

បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| [redacted] | | | |

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ០១កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០២៣

**ក្រឡាបញ្ជី**

[redacted]